ព្រះរាជាណាចក្រកម្ពុជា

តុលាការកំពូល

ជាតិ សាសនា ព្រះមហាក្សត្រ

សំណុំរឿងព្រហ្មទណ្ឌ

លេខ : ១៧

ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០៤

សាលដីកា

លេខ : ៤០

ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៥

# នាមនាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ ២០០៥ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជំរះដូចតទៅ :

| | | |
|---|---|---|
| ១- ឯកឧត្តម | **ឃឹម ប៊ុណ្ណ** | ប្រធាន |
| ២- លោក | ឈឹម ស៊ីផល | ចៅក្រម |
| ៣- លោក | ជីវ កេង | ចៅក្រម |
| ៤- លោក | យស់ សូខឿន | ចៅក្រម-របាយការណ៍ |
| ៥- លោក | ស៊ិន ឌឹម | ចៅក្រម |

ក្រឡាបញ្ជី

លោក សុខ ប៊ុនសង

តំណាងមហាអយ្យការ

ឯកឧត្តម **ជួន ស៊ុនឡេង** អគ្គព្រះរាជអាជ្ញារង

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខ ពីសាលដីកាព្រហ្មទណ្ឌលេខ១៨៤ ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ នៃសំណុំរឿងព្រហ្មទណ្ឌលេខ១៧ ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០៤ របស់តុលាការកំពូល ។

***ចំណុច*** : ក្បត់សេចក្តីទុកចិត្ត ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីខែកុម្ភៈ ឆ្នាំ១៩៩៦ ។ បទល្មើសព្រហ្មទណ្ឌដែលមានចែង និង ផ្តន្ទាទោសតាមបញ្ញត្តិមាត្រាទី៤៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

-ជនជាប់ចោទឈ្មោះគួច ផល្លីន (ជាម្ចាស់បណ្តឹងសាទុក្ខ) ភេទស្រី អយុ៤៥ឆ្នាំ ជាតិខ្មែរ កើតនៅភូមិលោភ ឃុំសន្ទុង ស្រុកត្រាំង ខេត្តតាកែវ ទីលំនៅសព្វថ្ងៃផ្ទះលេខ១៣ ក្រុមទី០១សង្កាត់ច្រាំងចំរេះទី២ ខ័ណ្ឌឫស្សីកែវ ក្រុងភ្នំពេញ ប្តីឈ្មោះចាន់ ស៊ីថន មានកូន០៣នាក់ ។ ឪពុកឈ្មោះព្រហ្ម គួច"ស" ម្តាយឈ្មោះអ៊ុច អេន "ស" ទោសពីមុនគ្មាន នៅក្រៅឃុំ ។

-មេធាវី : គ្មាន

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះលឹម ដាវី (ជាចុងបណ្តឹងសាទុក្ខ) ភេទស្រី អាយុ៤១ឆ្នាំ ជាតិខ្មែរ មុខរបរនៅផ្ទះ ទីលំនៅសព្វថ្ងៃផ្ទះលេខ៥៩BE₀ សង្កាត់បឹងព្រលិត ខ័ណ្ឌ៧មករា ក្រុងភ្នំពេញ ។ ឪពុកឈ្មោះអ៊ុច លឹម "រ" ម្តាយឈ្មោះឡុង សន "រ" ប្តីឈ្មោះខាត់ សាម៉េត មានកូន០៣នាក់ ។

-មេធាវី : គ្មាន

តាមពាក្យបណ្តឹង ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ១៩៩៥របស់ឈ្មោះលឹម ដាវី ប្តឹងទាមទារប្រាក់ជំពាក់ចំនួន១៦.០០០$USD ពីឈ្មោះតួច ផល្លីន និង ប្តីឈ្មោះចាន់ ស៊ីថន ។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ អមតុលាការក្រុងភ្នំពេញថា : ធាតុព្រហ្មទណ្ឌមិនអាចរលត់បានឡើយដោយហេតុថា អំពើល្មើសនេះបានកើតឡើងមុនរួចទៅហើយ ទើបមានការទូទាត់ជាក្រោយ ដូច្នេះត្រូវតែចោទប្រកាន់ពីបទក្បត់សេចក្តីទុកចិត្ត តាមមាត្រាទី៤៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ០៨"ខ" ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ របស់តុលាការក្រុងភ្នំពេញ ដែលបានសំរេច :

១-លើកលែងចោទប្រកាន់ តួច ផល្លីន ភេទស្រី អាយុ៤៥ឆ្នាំ ជាតិខ្មែរ សាសនាព្រះពុទ្ធ របររកស៊ីលក់មាំុឆ្លុង កិតវប្បធម៌ថ្នាក់ទី៦ចាស់ មានទីលំនៅផ្ទះលេខ១៣ ក្រុមទី០១ សង្កាត់ច្រាំងចំរេះទី២ ខ័ណ្ឌឫស្សីកែវ ក្រុងភ្នំពេញ ប្តីឈ្មោះចាន់ ស៊ីថន មានកូន០៣នាក់ ។ ឪពុកឈ្មោះព្រហ្ម តួច "ស" ម្តាយឈ្មោះអ៊ួច អេន "ស" ពីបទរំលោភលើទំនុកចិត្តចាប់ពីថ្ងៃនេះតទៅ ។

២-ទុកសិទ្ធិអោយឈ្មោះលឹម ដាវី ជាដើមបណ្តឹងរដ្ឋប្បវេណីប្តឹងទាមទារសំណងនៅតុលាការរដ្ឋប្បវេណីជាសមត្ថកិច្ច ។

៣-សាលក្រមនេះ ប្រកាសជាសាធារណៈចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី កំបាំងមុខជនជាប់ចោទ បើកផ្លូវប្តឹងទាស់ និង បើកផ្លូវប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

-បានឃើញបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ របស់លោកព្រះរាជអាជ្ញារង អមតុលាការក្រុងភ្នំពេញ ប្តឹងមិនសុខចិត្តពីសាលក្រមព្រហ្មទណ្ឌលេខ០៨"ខ" ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ របស់តុលាការក្រុងភ្នំពេញ ត្រង់សេចក្តីសំរេចលើកលែងចោទប្រកាន់លើឈ្មោះតួច ផល្លីន ពីបទរំលោភលើទំនុកចិត្ត ។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមសាលាឧទ្ធរណ៍ថា : គួរបដិសេធសាលក្រមលេខ០៨"ខ" ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ របស់តុលាការក្រុងភ្នំពេញ ចោលជាអសារបង់ និង ចោទប្រកាន់លើឈ្មោះតួច ផល្លីន ពីបទរំលោភលើសេចក្តីទុកចិត្ត តាមមាត្រា៤៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ១៨៤ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ១៩៩៩របស់សាលាឧទ្ធរណ៍ ដែលបានសំរេច :

១-ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ របស់លោកព្រះរាជអាជ្ញារង អមតុលាការក្រុងភ្នំពេញ ធ្វើឡើងត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

២-ផ្តន្ទាទោសឈ្មោះគួច ជល្លីន ភេទស្រី អាយុ៤៥ឆ្នាំ ជាតិខ្មែរ កើតនៅភូមិលោភ ឃុំសន្លុង ស្រុកទ្រាំង ខេត្តតាកែវ ករិតវប្បធម៌ថ្នាក់ទី៦ចាស់ កាន់សាសនាព្រះពុទ្ធ ទីលំនៅសព្វថ្ងៃផ្ទះលេខ ១៣ ក្រុម០១ សង្កាត់ច្រាំងចំរេះទី II ខ័ណ្ឌឬស្សីកែវ ក្រុងភ្នំពេញ ដាក់ពន្ធនាគារកំណត់០២ឆ្នាំ តែទោស ត្រូវព្យួរកំណត់០៥ឆ្នាំ គិតពីថ្ងៃដែលសាលដីកានេះចូលជាស្ថាពរ ។ តាមមាត្រា៤៦ ,៦៨ និង ៧០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

៣-បង្គាប់អោយឈ្មោះគួច ជល្លីន សងថ្លៃរថយន្តជាប្រាក់ចំនួន១៦៨០ដុល្លាអាមេរិក បន្ថែមលើប្រាក់ដែលបានសងលើកមុន ថ្លៃឈ្នួលរថយន្តបីខែ ចំនួន៩០០ដុល្លាអាមេរិក និង ជម្ងឺចិត្តចំនួន ២០០ដុល្លាអាមេរិក ទៅអោយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះលឹម ដារី នៅពេលដែលសាលដីកានេះចូលជាស្ថាពរ ការទាមទារលើសពីនេះរបស់ដើមបណ្តឹងរដ្ឋប្បវេណីលើកចោល ។

សំរេចដាក់គុកបង្ខំរូបកាយតាមមាត្រា៧ នៃច្បាប់ស្តីពីការដាក់គុកបង្ខំលើរូបកាយ ដើម្បីទារប្រាក់ធនទណ្ឌក្នុងរឿងព្រហ្មទណ្ឌ ក្នុងករណីដែលទណ្ឌិតគ្មានប្រាក់សង ឬ រឹងរូសមិនព្រមសង ។

៤-សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈកំបាំងមុខជនជាប់ចោទ និង ដើមបណ្តឹងរដ្ឋប្បវេណី សំរេចបើកផ្លូវប្តឹងទាស់ និង ប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

-បានឃើញបណ្តឹងសាទុក្ខលេខ៥៤ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៣ របស់ឈ្មោះគួច ជល្លីន ប្តឹងមិនសុខចិត្តពីសាលដីកាព្រហ្មទណ្ឌលេខ១៨៤ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល ។

-បានឃើញសារណា របស់ឈ្មោះគួច ជល្លីន ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៤ ។

-បានឃើញសារណាតប របស់ឈ្មោះលឹម ដារី ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០០៤ ។

- បានស្តាប់ចៅក្រមរបាយការណ៍ អានរបាយការណ៍

- បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមតុលាការកំពូល ថា : រឿងនេះមានបទរំលោភលើសេចក្តីទុកចិត្តប្រាកដមែន ។

-បានស្តាប់ចម្លើយអះអាងរបស់ជនជាប់ចោទឈ្មោះគួច ជល្លីន ( ជាម្ចាស់បណ្តឹងសាទុក្ខ) នៅពេលជំនុំជំរះថា :បានជានាងខ្ញុំប្តឹងសាទុក្ខមកតុលាការកំពូល ព្រោះនាងខ្ញុំអត់លុយសងទៅគាត់វិញ ព្រោះឡាននោះនាងខ្ញុំ អត់បានជួលទេ ដោយគាត់ព្រមព្រៀងឱ្យប្តីខ្ញុំយកទៅរត់ដោយការរាប់អានគ្នា តែក្រោយមកនាងខ្ញុំត្រូវគេ បង្ខំឱ្យលក់ឡាននោះ ព្រោះឡាននោះបានបុកគេ កាលពេលលក់នោះក៏មានធ្វើសំបុត្រទិញ-លក់ដែរ ។ ប៉ុន្តែខ្ញុំបានសងលុយគាត់វិញមួយចំនួនហើយ ។

-បានស្តាប់ចម្លើយអះអាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះលឹម ដារី (ជាចុងបណ្តឹងសាទុក្ខ) នៅពេលជំនុំជំរះថា : កាលពីមុននាងខ្ញុំបានធ្វើការនៅរតនាគារជាតិ ហើយពេលនាងខ្ញុំចេញពីធ្វើការ នាងខ្ញុំតែងតែទៅផ្សារជាពិសេសកន្លែង គួច ជល្លីន នេះ ។ ពេលនោះគាត់ចេះតែបញ្ចុះបញ្ចូលខ្ចីលុយខ្ញុំអស់រាប់ម៉ឺន រហូតឱ្យនាងខ្ញុំទិញឡានឱ្យប្តីគាត់រត់ តែតាំងពីទិញឡាននោះឱ្យទៅលុយមិនសង ថ្លៃឈ្នួលឡានក៏

មិនដែលឱ្យ រហូតដល់គាត់ហ៊ានលក់ឡាននោះបាត់ទៀត ដោយមិនបានប្រាប់នាងខ្ញុំ តែនាងខ្ញុំបានទទួលលុយពីគាត់២១០០$ ដែរ ។ ចំពោះការប្តឹងឧទ្ធរណ៍នោះ ខ្ញុំអាងតែព្រះរាជអាជ្ញាប្តឹងហើយ គឺស្មានថាគិតទាំងសំណងទាំងទណ្ឌកម្ម ខ្ញុំចង់ទៅប្តឹងដែរ តែខាងតុលាការក្រុងចេះតែថា មិនដឹងទីណា ដូច្នេះនាងខ្ញុំឱ្យតុលាការកំពូលសំរេចឱ្យជនជាប់ចោទសងលុយខ្ញុំវិញ និង ដាក់ទោសទៅតាមច្បាប់ ព្រោះជនជាប់ចោទនេះបានបោកខ្ញុំអស់រយៈពេល១១ឆ្នាំទៅហើយ ហើយចេះតែរួចខ្លួនជានិច្ច ។

-បានស្តាប់សេចក្តីសន្និដ្ឋានបន្ថែមរបស់តំណាងមហាអយ្យការ អមតុលាការកំពូល នៅពេលជំនុំជំរះថា : វាមានបណ្តឹងអាជ្ញាហើយ ដូច្នេះរឿងនេះនៅតែជាបទល្មើសរំលោភលើសេចក្តីទុកចិត្តដដែល ។

-ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ និង ដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ ។

## តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ៥៤ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៣ របស់ឈ្មោះតូច ជល្វីនធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ។

-យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សំរេចលើបណ្តឹងឧទ្ធរណ៍ របស់តំណាងអយ្យការអោយជនជាប់ចោទសងប្រាក់ថ្លៃឈ្នួលរថយន្ត និង ជំងឺចិត្តទៅដើមបណ្តឹងរដ្ឋប្បវេណី ដោយដើមបណ្តឹងរដ្ឋប្បវេណីឥតបានប្តឹងឧទ្ធរណ៍ ពីសាលក្រមចំពោះមុខរបស់តុលាការក្រុងភ្នំពេញនោះ គឺជាការបំពានលើគោលការណ៍នៃមាត្រា ៥, ៦, ៩, ១០, ១៤ នៃច្បាប់នីតិវិធីព្រហ្មទណ្ឌ ពីព្រោះព្រះរាជអាជ្ញាមិនអាចប្តឹងឧទ្ធរណ៍ ដើម្បីទាមទារសំណងរដ្ឋប្បវេណីជំនួសជនរងគ្រោះបានទេ ។ ព្រះរាជអាជ្ញាមានសមត្ថកិច្ចតែលើបណ្តឹងអាជ្ញាប៉ុណ្ណោះ ។

-យល់ឃើញថា សាលាឧទ្ធរណ៍បានសំរេចទទួលបណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ហើយ ប៉ុន្តែសាលាឧទ្ធរណ៍ពុំបានសំរេចបដិសេធសាលក្រមរបស់តុលាការក្រុងភ្នំពេញចោលទេ បែរជាមកសំរេចផ្តន្ទាទោសជនជាប់ចោទ និងឱ្យសងទៅដើមបណ្តឹងរដ្ឋប្បវេណី ដោយពុំមានបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី ។ ការសំរេចបែបនេះ ជាការរំលោភយ៉ាងធ្ងន់ធ្ងរលើច្បាប់នីតិវិធីព្រហ្មទណ្ឌ ។

-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ១៨៤ ចុះថ្ងៃទី២១-៧-១៩៩៩ របស់សាលាឧទ្ធរណ៍ដែលបានសំរេចសេចក្តីមកនេះមានលក្ខណៈខុសឆ្គងទាំងទំរង់ ទាំងគតិច្បាប់ហើយ ។

## ហេតុដូច្នេះ

*វិនិច្ឆ័យសេចក្តីចំពោះមុខជនជាប់ចោទ និង ដើមបណ្តឹងរដ្ឋប្បវេណី*

១-ទទួលបណ្តឹងសាទុក្ខលេខ៥៤ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៣ របស់ឈ្មោះ តួច ផល្លីន ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២-ទុកជាមោឃៈសាលដីកាព្រហ្មទណ្ឌលេខ១៨៤ ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣-បង្វិលសំណុំរឿងព្រហ្មទណ្ឌលេខ១៧ ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០៤ របស់តុលាការកំពូលទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤-សាលដីកានេះប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៥ ។